**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គ ជ អ ប
NCDD

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

ថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៥

# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាស្តីពីការផ្សព្វផ្សាយលទ្ធផល និងបិទបញ្ចប់គម្រោង «ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (STA Project)»

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) សូមជូនដំណឹងដល់សាធារណជន និងបណ្តាញសារព័ត៌មានទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរៀបចំកិច្ចប្រជុំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយលទ្ធផល និងបិទបញ្ចប់គម្រោង «ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (STA Project)» នៅថ្ងៃព្រហស្បតិ៍ ១១រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥ នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ ចាប់ពីម៉ោង ៨:០០នាទីព្រឹក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ចាន់ សុធា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.ក្នុងពិធីបើកកម្មវិធី។

សិក្ខាសាលានេះ នឹងពិភាក្សាទៅលើរបៀបវារៈ សំខាន់ៗ ដូចខាងក្រោម៖

១. បទបង្ហាញអំពីទិដ្ឋភាពទូទៅគម្រោង «ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (STA Project)»
២. បទបង្ហាញសមិទ្ធផល (Outcome) នៃការអនុវត្តគម្រោង STA Project ដោយលេខាធិការដ្ឋាន គ.ជ.អ.ប.
៣. បទបង្ហាញសមិទ្ធផល (Outcome) នៃការអនុវត្តគម្រោង STA Project របស់អង្គការសង្គមស៊ីវិល
៤. បទបង្ហាញសមិទ្ធផល (Outcome) នៃការអនុវត្តគម្រោង STA Project ក្នុងការផ្តល់ព័ត៌មាន និងទទួលមតិយោបល់ត្រលប់ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលរបស់ក្រុងគោលដៅ
៥. កិច្ចពិភាក្សា (Panel Discussion)៖ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន
៦. ការចែករំលែក និងផ្សព្វផ្សាយអំពីគេហទំព័ររបស់ គ.ជ.អ.ប.
៧. ការចែករំលែកបទពិសោធន៍ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋតាមរយៈថ្នាលឌីជីថល
៨. របាយការណ៍បូកសរុបលទ្ធផលសិក្ខាសាលា

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមអញ្ជើញអ្នកសារព័ត៌មានទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

*សូមទាក់ទងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមុនតាមរយៈ៖*
*លេខទូរស័ព្ទ ៖ លោក សួង ថុន ០១២ ៩៦០ ៨០៨ /លោក កែវ សំរិត ០១៧ ៦៧៨ ៤៨៨*